

## ការដាក់នុយ

ការដាក់នុយទាក់ទងនឹងការដាក់នុយសរីរាង្គ ទៅនឹងផ្នែកសមរម្យនៃដើមដែលមានស្លឹកច្រើន ទាំងនៅទីធ្លាខាងមុខ និងទីធ្លាខាងក្រោយផ្ទះ។

នេះរួមមាន៖

- ការដាក់នុយក្នុងបរិមាណ៤០មីលីលីត្រទៅកន្លែងមានរុក្ខជាតិលូតលាស់ដោយដាក់ប្រហែលជា១៥០កន្លែងក្នុងមួយហិកតា (នេះស្មើនឹងនុយប្រហែល ១២កន្លែងក្នុងអចលនទ្រព្យមួយ)
- ការដាក់នុយសរីរាង្គឡើងវិញជាទៀងទាត់ រហូតទាល់តែយើងខ្ញុំជឿជាក់ថារុយចោះផ្លែឈើពេញវ័យត្រូវបានគ្រប់គ្រង
- ប្រសិនបើអចលនទ្រព្យរបស់អ្នកស្ថិតនៅក្នុងចម្ងាយ២០០ម៉ែត្រពីទីតាំងដែលបានរកឃើញនោះ ការដាក់នុយនឹងត្រូវអនុវត្តពីរដងក្នុងមួយសប្តាហ៍។ ផ្នែកផ្សេង ទៀតនៃតំបន់ផ្ទុះរាតត្បាត នឹងត្រូវបានដាក់នុយម្តងក្នុងមួយសប្តាហ៍។

ការដាក់នុយជាធម្មតាចំណាយពេលពី៦ ទៅ៨សប្តាហ៍ អាស្រ័យលើចំនួនរុយចោះផ្លែឈើដែលបានរកឃើញ។ បន្ទាប់ពីពេលនេះ ការដាក់នុយនឹងត្រូវបានឈប់ ហើយរុយដែលមិនអាចបន្តពូជអាចត្រូវបានដោះលែងនៅក្នុងតំបន់។

ការដាក់នុយនេះមានប្រសិទ្ធិភាពបំផុត ពេលណាបានដាក់នៅទីធ្លាខាងក្រោយនៃអចលនទ្រព្យក្នុងតំបន់ផ្ទុះរាតត្បាត ដោយព្រោះថានេះគឺជាកន្លែងដែលគេឃើញ មានរុយចោះផ្លែឈើញឹកញាប់បំផុត។ ប្រសិនបើមិនអាចធ្វើទៅបានទេ នុយនឹងត្រូវបានដាក់ទៅនឹងផ្នែកសមរម្យនៃដើមដែលមានស្លឹកច្រើនផ្សេងទៀតនៅក្នុង អចលនទ្រព្យរបស់អ្នក។

ក្រុមកំណត់កន្លែងដាក់នុយរបស់យើងខ្ញុំ អាចមកកាន់អចលនទ្រព្យរបស់អ្នកដែលជាផ្នែកនៃកម្មវិធីលុបបំបាត់។

## អនាម័យ (ការប្រមូលផ្លែឈើ)

អនាម័យទាក់ទងនឹងការប្រមូលផ្លែឈើដែលធ្លាក់ជ្រុះ ចេញពីទីធ្លាពេញទូទាំងតំបន់ផ្ទុះរាតត្បាត។ នៅទីតាំងស៊ើបរកជាកន្លែងដែលរកឃើញដង្កូវរុយចោះផ្លែឈើ  ផ្លែឈើទាំងអស់នឹងត្រូវបានបេះប្រមូលចេញពីដើម។ ពេលការផ្ទុះរាតត្បាតត្រូវបានប្រកាសហើយនោះ បុគ្គលិកនឹងវាយតម្លៃអចលនទ្រព្យនៅក្នុងតំបន់ដាក់ឱ្យនៅ ដាច់ពីគេ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ប្រសិនបើអ្នកមានដើមឈើហូបផ្លែនៅក្នុងទីធ្លាខាងក្រោយផ្ទះរបស់អ្នក ក្រុមការងារអនាម័យរបស់យើងខ្ញុំនឹងចុះ ទៅមើលអចលនទ្រព្យរបស់អ្នក ម្តងក្នុងមួយសប្តាហ៍ក្នុងអំឡុងពេលកម្មវិធីលុបបំបាត់។

## សារៈសំខាន់នៃការគ្មានរុយចោះផ្លែឈើ

រដ្ឋអូស្ត្រាលីខាងត្បូងគឺជារដ្ឋដីគោកអូស្ត្រាលីតែមួយគត់ដែលគ្មានរុយចោះផ្លែឈើ ។ ស្ថានភាពនេះមានអត្ថប្រយោជន៍យ៉ាងច្រើនដល់រដ្ឋរបស់យើង រួមមាន៖

- ការពារផលិតកម្មពាណិជ្ជកម្មផ្លែឈើ បន្លែ ស្រាទំពាំងបាយជូរ និងអាល់ម៉ុនជាពិសេសនៅតំបន់ Riverland និង Murraylands។ តម្លៃប៉ាន់ស្មានកសិផលតាមច្រកចំការគឺប្រហែល១.៣ពាន់លានដុល្លារ។
- ធានាលទ្ធភាពទទួលបានទីផ្សារនាំចេញដែលផ្តល់ផលចំណេញច្រើន រួមមានប្រទេសជប៉ុន អាមេរិក និងញូវហ្សេឡែន ដែលមានតម្លៃប្រហែល៧២លានដុល្លារ ក្នុងឆ្នាំ២០១៨-១៩
- សមត្ថភាពរបស់ពលរដ្ឋដើម្បីដាំដុះផ្លែឈើ និងបន្លែនៅតាមផ្ទះដោយប្រើថ្នាំសម្លាប់សត្វល្អិតតិចជាងមុន។

ការគ្មានរុយចោះផ្លែឈើ មានន័យថា អ្នកអាចដាំដុះផ្លែឈើ និងពពួកបន្លែមានផ្លែរបស់អ្នកដោយមានការធានាថាមិនមានដង្កូវរុយ។

## ការដោះលែងរុយចោះផ្លែឈើដែលមិនអាចបន្តពូជ

ដោះលែងរុយចោះផ្លែឈើដែលមិនអាចបន្តពូជ ជួនកាលត្រូវបានប្រើពេលណាការដាក់នុយ និងការងារអនាម័យបានបញ្ចប់។

ដើម្បីឱ្យមានប្រសិទ្ធភាព នុយអាចកាត់បន្ថយចំនួនសត្វរុយព្រៃដែលឃើញមាននៅក្នុងតំបន់ផ្ទុះរាតត្បាត។

រុយចោះផ្លែឈើដែលមិនអាចបន្តពូជ  ជាធម្មតាត្រូវបានដោះលែងចេញពីឧបករណ៍នៅខាងក្រោយរថយន្តដែលបើកយឺតៗកាត់តំបន់ផ្ទុះរាតត្បាត។

ផ្នែកនៃកម្មវិធីលុបបំបាត់នេះ អាចចំណាយពេលរហូតដល់ទៅ១២សប្តាហ៍ ហើយមិនចាំបាច់ចូលទៅកាន់ទីធ្លាខាងក្រោយផ្ទះឡើយ។

ការរួមបញ្ចូលគ្នានៃការកំណត់កន្លែងដាក់នុយ និងបច្ចេកវិទ្យាមិនឱ្យសត្វល្អិតអាចបន្តពូជ បច្ចុប្បន្ននេះគឺជាការអនុវត្តដ៏ល្អបំផុតរបស់ពិភពលោកក្នុងការលុបបំបាត់រុយចោះផ្លែឈើ។

## ការដាក់អន្ទាក់

អន្ទាក់ឃ្លាំមើលអាចត្រូវបានដំឡើងនៅក្នុង ឬក្បែរទីធ្លារបស់អ្នក។

អន្ទាក់នេះមានដាក់នុយសរីរាង្គ - មានសុវត្ថិភាពសម្រាប់មនុស្ស និងសត្វចិញ្ចឹម - ដែលទាក់ទាញ និងសម្លាប់រុយចោះផ្លែឈើ។

បុគ្គលិករបស់យើងខ្ញុំនឹងត្រូវការចូលទៅកាន់ទីធ្លារបស់អ្នកដើម្បីព្យួរអន្ទាក់នៅលើដើមឈើមួយ ហើយម្តងម្កាលនឹងត្រូវទៅមើលដើម្បីដាក់នុយថ្មី។

## ទាក់ទងមកយើងខ្ញុំ

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីរុយចោះផ្លែឈើ៖ **1300 666 010** ឬចូលមើលនៅតាមវិបសៃថ៍ **pir.sa.gov.au/fruitfly**

*ព័ត៌មាននៅក្នុងខិត្តប័ណ្ណនេះអាចមានផ្តល់ជូនតាមការស្នើសុំជាទម្រង់មួយផ្សេងទៀត ឬជាភាសាផ្សេងទៀតសម្រាប់អស់អ្នកដែលត្រូវ ការវា។ សូមទំនាក់ទំនង PIRSA សម្រាប់ព័ត៌មានបន្ថែម។*

Khmer / ខ្មែរ

PIRSA

# ការផ្ទុះរាតត្បាតនៃរុយចោះផ្លែឈើ

## វិធានការដាក់ឱ្យនៅដាច់ពីគេកំពុងដំណើរការនៅក្នុងតំបន់របស់អ្នក ទាំងនេះរួមមានការរឹតត្បិតលើចលនានៃបន្លែ និងផ្លែឈើដែល ដាំដុះតាមផ្ទះ។



SOUTH AUSTRALIA

Government of South Australia
Primary Industries and Regions SA





# ជូនចំពោះម្ចាស់ក្រុមគ្រួសារ

**អចលនទ្រព្យ (ផ្ទះ ឬចំការដីធ្លី) របស់អ្នកស្ថិតនៅក្នុងតំបន់ផ្ទុះរាតត្បាតនៃរុយចោះផ្លែឈើ។**

ពេលណាការផ្ទុះរាតត្បាតនៃរុយចោះផ្លែឈើត្រូវបានប្រកាស ឧស្សាហកម្មវត្ថុធាតុដើម និងតំបន់រដ្ឋអូស្ត្រាលីខាងត្បូង (PIRSA) អនុវត្តកម្មវិធីលុបបំបាត់រុយចោះ ផ្លែឈើ។

ព័ត៌មាននេះគឺដើម្បីជូនដំណឹងដល់អ្នក អំពីរុយចោះផ្លែឈើ និងកម្មវិធីលុបបំបាត់ដែលកំពុងដំណើរការ។

## តើរុយចោះផ្លែឈើគឺជាអ្វី?

រុយចោះផ្លែឈើគឺជាសត្វល្អិតដ៏ចង្រៃដែលបំផ្លាញរុក្ខជាតិ ហើយអាចបំផ្លាញផ្លែឈើ និងបន្លែនៅក្នុងជំណាំពាណិជ្ជកម្ម និងសួនច្បារនៅតាមផ្ទះ។ រុយចោះផ្លែឈើពីមួយអាចពងដាក់ផ្លែឈើ និងបន្លែ រួមមាន៖

- ពពួកផ្លែឈើមានគ្រាប់រឹង (អាព្រីខុត ភីជ ណិកតារីន ផ្លាំ និងឈែរី)
- ពពួកផ្លែក្រូច (ក្រូច ក្រូចឆ្មារ ក្រូចថ្លុង និងខាំឃ្វិត (cumquat))
- ពពួកបន្លែមានផ្លែ (ប៉េងប៉ោះ ម្ទេសផ្លោក ម្ទេស ត្រប់សណ្តាយ និងថាម៉ារីឡូ (tamarillo))
- ពពួកផ្លែប៉ោមមានស្នូលដាក់គ្រាប់ (ប៉ោម ភែរ និងឃ្វីន្ស (quince))
- ពពួករុក្ខជាតិដាក់ផ្កា (ឡូឃ្វិត (loquat) ល្វា និងហ្វេចូអា (feijoa))
- ពពួកផ្លែឈើត្រូពិក (ចេក និងស្វាយ)។

## តើការផ្ទុះរាតត្បាតនៃរុយចោះផ្លែឈើត្រូវបានប្រកាសយ៉ាងដូចម្តេច?

ការផ្ទុះរាតត្បាតនៃរុយចោះផ្លែឈើត្រូវបានប្រកាស ពេលណាមានការរកឃើញនៃរុយចោះផ្លែឈើ ឬពងរុយ។

ការរកឃើញអាចកើតឡើងតាមរយៈផ្លែឈើដែលមានពេញទៅដោយដង្កូវរុយ ឬតាមរយៈវត្តមាននៃសត្វរុយនៅក្នុងអន្ទាក់ឃ្លាំមើលរបស់យើង។

ពេលណាការផ្ទុះរាតត្បាតត្រូវបានប្រកាស តំបន់ដាក់ឱ្យនៅដាច់ពីគេចម្ងាយ១.៥គីឡូម៉ែត្រត្រូវបានបង្កើតឡើងនៅជុំវិញទីតាំងដែលបានរកឃើញនោះ ហើយកម្មវិធីលុបបំបាត់នឹងចាប់ផ្តើមដំណើរការ។

## អ្វីដែលអ្នកចាំបាច់ត្រូវធ្វើ

ច្បាប់ស្តីពី*សុខភាពរុក្ខជាតិ ឆ្នាំ២០០៩* ផ្តល់សិទ្ធិដល់បុគ្គលិក PIRSA ក្នុងការចូលទៅកាន់ទ្រព្យសម្បត្តិដើម្បីបំពេញមុខការចាំបាច់នេះ ដូច្នេះសូមធានាថាបុគ្គលិករបស់យើងខ្ញុំអាចចូលទៅកាន់ទីធ្លារបស់អ្នកបាន។ ប្រសិនបើអ្នកមានឆ្កែ សូមរក្សាចងវាឱ្យបានជាប់ ខណៈពេលបុគ្គលិករបស់យើងខ្ញុំមានវត្តមាននៅទីនោះ។

### សូមកុំផ្លាស់ទីផ្លែឈើស្រស់ៗដែលដាំដុះតាមផ្ទះនៅក្នុងតំបន់ផ្ទុះរាលដាល

អ្នកមិនត្រូវយកផ្លែឈើដែលដាំដុះតាមផ្ទះ ពពួកបន្លែមានផ្លែ ឬកាកសំណល់សួនច្បារចេញពីអចលនទ្រព្យរបស់អ្នកឡើយ។ អ្នកមិនអាចយកផ្លែឈើស្រស់ៗដាក់ ក្នុងប្រអប់អាហារថ្ងៃត្រង់សម្រាប់ការងារ ឬសាលារៀនបានទេ ប្រសិនបើអ្នកនឹងបរិភោគវានៅក្រៅតំបន់ដាក់ឱ្យនៅដាច់ពីគេ។

អ្នកអាចដាក់ផ្លែឈើ និងបន្លែដែលអ្នកមិនចង់បានទៅក្នុងធុងពណ៌បៃតងរបស់អ្នកដូចធម្មតា។ យើងខ្ញុំបានធ្វើការជាមួយសាលាក្រុងក្នុងតំបន់របស់អ្នកលើប្រព័ន្ធសម្រាប់ការបោះចោលកាកសំណល់ពណ៌បៃតង ក្នុងអំឡុងពេលផ្ទុះរាតត្បាតនៃរុយចោះផ្លែឈើ។

- ✓ សូមផ្តល់លទ្ធភាពដើម្បីចេញចូលសួនច្បារខាងមុខ និងខាងក្រោយផ្ទះរបស់អ្នក ដើម្បីឱ្យបុគ្គលិក PIRSA អាចបញ្ចប់កិច្ចការរបស់ពួកគេបានយ៉ាងឆាប់រហ័ស។
- ✓ រាយការណ៍អំពីដង្កូវរុយណាមួយដែលរកឃើញនៅក្នុងផ្លែឈើ ឬពពួកបន្លែមានផ្លែ រួមទាំងបន្លែផ្លែឈើដែលអ្នកបានទិញពីហាង។ ដាក់វាទៅក្នុងថង់ប្លាស្ទិច បិទមាត់វាឱ្យជិត ហើយទាក់ទងទៅ**ខ្សែទូរស័ព្ទទាន់ហេតុការណ៍ស្តីពីរុយចោះផ្លែឈើ លេខ (1300 666 010)** ដើម្បីរៀបចំការប្រមូល។
- ✓ ប្រមូលផ្លែឈើ និងពពួកបន្លែមានផ្លែដែលទុំជ្រុះ ហើយដាក់វាចូលទៅក្នុងធុងពណ៌បៃតងរបស់អ្នក។ កុំដាក់វានៅក្នុងជីកំប៉ុស។
- ✓ ចម្អិន ឬរក្សាទុកផ្លែឈើ និងពពួកបន្លែមានផ្លែដែលដាំដុះតាមផ្ទះដែលនៅសេសសល់។ ផ្លែឈើទាំងនេះអាចអនុញ្ញាតឱ្យយកចេញពីតំបន់ដាក់ឱ្យនៅដាច់ពីគេ បាន។
- ✗ កុំទុកផ្លែឈើ និងពពួកបន្លែមានផ្លែដែលដាំដុះតាមផ្ទះឱ្យនៅរាយប៉ាយលើដីធ្លី។
- ✗ កុំធ្វើជីកំប៉ុសផ្លែឈើ និងពពួកបន្លែមានផ្លែណាមួយ រួមទាំងបន្លែដែលបានទិញពីហាងក្នុងអំឡុងពេលដាក់ឱ្យនៅដាច់ពីគេ។

## តើការដាក់ឱ្យនៅដាច់ពីគេនឹងមានរយៈពេលយូរប៉ុន្មាន?

រយៈពេលនៃការដាក់ឱ្យនៅដាច់ពីគេអាចប្រែប្រួល ដោយព្រោះថាវាត្រូវបានកំណត់ដោយចំនួនសត្វរុយដែលបានរកឃើញក្នុងអំឡុងពេលដាក់លាក់ក្រោមពិធីការ ជាតិស្តីពីការគ្រប់គ្រងរុយចោះផ្លែឈើ ។

យើងខ្ញុំដឹងថាការរឹតបន្តឹងលើការដាក់ឱ្យនៅដាច់ពីគេ និងកម្មវិធីលុបបំបាត់នឹងបណ្តាលឱ្យមានការរអាក់រអួលខ្លះ ប៉ុន្តែកិច្ចសហប្រតិបត្តិការរបស់អ្នកនឹងជួយយើង ខ្ញុំយ៉ាងខ្លាំង ក្នុងការរក្សាកុំឱ្យមានរុយចោះផ្លែឈើក្នុងរដ្ឋអូស្ត្រាលីខាងត្បូង។

នៅពេលបញ្ចប់កម្មវិធីលុបបំបាត់ យើងខ្ញុំនឹងជូនដំណឹងមកអ្នកតាមរយៈខិត្តប័ណ្ណ។ មានតែបន្ទាប់ពីពេលនេះទេដែលអ្នកអាចយកផ្លែឈើ និងបន្លែដែលដាំដុះតាម ផ្ទះ ចេញពីអចលនទ្រព្យរបស់អ្នកបាន។

## តើមានអ្វីកើតឡើងក្នុងអំឡុងពេលកម្មវិធីលុបបំបាត់?

បុគ្គលិករបស់ PIRSA ចុះទៅអចលនទ្រព្យដើម្បីអនុវត្តកិច្ចការដាក់នុយ និងអនាម័យ។

បុគ្គលិករបស់យើងខ្ញុំមានសម្លៀកបំពាក់អាវជាប់ខោពណ៌ទឹកក្រូច និងកាន់អត្តសញ្ញាណប័ណ្ណ PIRSA។

ទាំងកិច្ចការដាក់នុយ និងអនាម័យនឹងបានចាប់ផ្តើមធ្វើនៅក្នុងតំបន់របស់អ្នកហើយ។

ពេលណាការដាក់នុយបានបញ្ចប់ហើយ យើងខ្ញុំអាចដោះលែងរុយចោះផ្លែឈើដែលមិនអាចបន្តពូជនៅក្នុងតំបន់ផ្ទុះរាតត្បាត។ នេះនឹងការពាររុយចោះផ្លែឈើព្រៃដែលនៅសេសសល់ ពីការបង្កបង្កើតកូន។